**គណៈមេធាវីក្រុងប៉ារីស**

**ផ្នែកវិន័យ**

**លោក Arthur VEREKEN**
មេធាវីតុលាការ
ផ្ទះលេខ ២ ផ្លូវ DU CYGNE
៧៥០០១ ប៉ារីស

សេវាកម្មទទួលវិញ្ញាបនបត្រ ISO 9001
ចេញដោយ Bureau Veritas Certification

**ក្រុមប្រឹក្សាវិន័យ**
គណៈវិនិច្ឆ័យទី ១

លេខាធិការដ្ឋាន៖ Marie-Christine SAUNIER
ទូរសព្ទ៖ ០១ ៤៤ ៣២ ៤៨ ៨៤
ទូរសារ៖ ០១ ៤៦ ៣៤ ៧៧ ៦៥
អ៊ីមែល៖

ប៉ារីស ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥

**<u>សំបុត្រអនុសិដ្ឋ ដោយមានបង្កាន់ដៃទទួល</u>**

កម្មវត្ថុ៖ **អាជ្ញាធរ តទល់នឹង Arthur VERCKEN**
លេខយោង៖ សំណុំរឿងលេខ ៣០០/២៦៣៦៣០

សហភាតាជាទីមេត្រី!

យោងតាមបទប្បញ្ញត្តិនៃវិធាន ១៨៦ នៃក្រឹត្រ-ច្បាប់ លេខ ២០០៥-៥៣១ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៥ ដែលបានកែសម្រួលក្រឹត្យ-ច្បាប់ លេខ ៩១-១១៩៧ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ខ្ញុំមានកិត្តិយសជម្រាបជូនលោកអំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ពាក់ព័ន្ធនឹងករណីរបស់លោក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥។

សូមលោកសហភាគីទទួលនូវមនោសញ្ចេតនារាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

*[ហត្ថលេខា]*

**Étienne LESAGE**

**សមាជិកក្រុមប្រឹក្សាគណៈមេធាវី**

**លេខាធិការគណៈវិនិច្ឆ័យទី ១**

**ភ្ជាប់ជាមួយ**

**<u>សំខាន់÷ មាត្រា ៦៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងមាត្រា ១៦ នៃក្រឹត្យ-ច្បាប់ លេខ ៩១-១១៩៧ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩១</u>**

ក្នុងរយៈពេល**មួយខែ**ចាប់ពីកាលបរិច្ឆេទជូនដំណឹង សេចក្តីសម្រេចនេះអាចត្រូវបានបញ្ជូនទៅកាន់សាលាឧទ្ធរណ៍ក្រុងប៉ារីស តាមរយៈសេចក្តីប្រកាសទៅលេខាធិការដ្ឋានក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ឬតាមរយៈសំបុត្រអនុសិដ្ឋ ដោយមានបង្កាន់ដៃទទួល ផ្ញើទៅលេខាធិការដ្ឋានក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។

| |
|---|
| **លោកអគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ និងលោកប្រធានគណៈមេធាវី ត្រូវទទួលបានសេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចនេះ ឲ្យបានឆាប់រហ័សបំផុត ដើម្បីចៀសវាងរាល់ការចាត់វិធានការអនុវត្តភ្លាមៗនូវសេចក្តីសម្រេចណាមួយ ដែលមិនត្រូវបានអនុញ្ញាតឲ្យអនុវត្តក្នុងរយៈពេលប្តឹងឧទ្ធរណ៍ឡ** |

# គណៈមេធាវីក្រុងប៉ារីស
# ក្រុមប្រឹក្សាវិន័យ

---

## សេចក្ដីសម្រេច ចេញថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥

---

**អាជ្ញាធរចោទប្រកាន់ តទល់នឹង Arthur VERCKEN**
**សំណុំរឿងលេខ÷ ៣០០/២៦៣៦៣០**

**គណៈវិនិច្ឆ័យទី១ នៃក្រុមប្រឹក្សាវិន័យ**

**ដោយរំឭកថា៖**

ក្រោយពីមានរបាយការណ៍ស៊ើបអង្កេតខាងវិន័យ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ របស់លោក Denis CHEMLA សមាជិកក្រុមប្រឹក្សាគណៈមេធាវី លោក Arthur VERCKEN ត្រូវបានកោះហៅ តាមរយៈលិខិតក្រៅផ្លូវតុលាការរបស់មេធាវី Eric CRUSSARD អាជ្ញាសាលាក្រុងប៉ារីស ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឲ្យមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាវិន័យ ដើម្បីចូលរួមសវនាការនៅថ្ងៃ អង្គារ ទី ១៣ ខែ តុលា ឆ្នាំ ២០១៥ វេលាម៉ោង ៩ ព្រឹក ដោយមានអង្គហេតុដូចរៀបរាប់ខាងក្រោម។

ក្រោយពីបញ្ចប់សវនាការខាងលើ ដែលត្រូវបានធ្វើឡើងជាសាធារណៈ ដោយមិនមានវត្តមានភាគីទទួលរងនូវការចោទប្រកាន់ និងក្រោយពីបានស្ដាប់ អនុលោមតាមបទប្បញ្ញត្តិនៃប្រការ P.72.5.11 និងប្រការ P.72.5.12 នៃបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីក្រុងប៉ារីស នូវ៖

- របាយការណ៍ផ្ទាល់មាត់របស់លោក Etienne LESAGE សមាជិកក្រុមប្រឹក្សាគណៈមេធាវី ដោយរួមបញ្ចូលទាំងការអានដីកាកោះ
- មូលវិចារណ៍របស់លោក Pierre-Olivier SUR ប្រធានគណៈមេធាវី និងលោក Jean-Marc FEDIDA សមាជិកក្រុមប្រឹក្សាគណៈមេធាវី ដែលជាតំណាងឲ្យអាជ្ញាធរចោទប្រកាន់

លោក Arthur VERCKEN ដែលអវត្តមានដោយសារតែមានធុរៈជាប់រវល់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ បានជម្រាបក្រុមប្រឹក្សាវិន័យពីបំណងរបស់គាត់ ឲ្យក្រុមប្រឹក្សាវិន័យធ្វើការសម្រេច ដោយមិនមានវត្តមានរបស់គាត់ ដោយលោកមេធាវីរំឭកថា គាត់ធ្លាប់ត្រូវបានស្តាប់ចម្លើយនៅចំពោះមុខអ្នករាយការណ៍ដូចសហភាតារបស់គាត់ លោកស្រី Anta GUISSÉ ដែរ ហើយគាត់ទាំងពីរបានដាក់សារណា បង្ហាញអំពីទឡ្ហីករណ៍របស់ខ្លួន។ លោក Arthur VERCKEN បានរំឭកថែមទៀតថា អង្គហេតុទាំងឡាយដែលរូបគាត់ត្រូវទទួលរងការចោទប្រកាន់ ដូចគ្នាទៅនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់លើលោកស្រី Anta GUISSÉ ហើយហេតុដូច្នេះ លោកមេធាវីសូមយកទឡ្ហីករណ៍របស់លោកស្រី Anta GUISSÉ មកការពារខ្លួនគាត់ដែរ។

**សម្រេចដូចតទៅ៖**

**I- អង្គហេតុ**

អង្គហេតុត្រូវបានរៀបរាប់ នៅក្នុងដីកាកោះ ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ៖

*"១- __ស្ថានភាពរដ្ឋបាល__*

*លោក Arthur VERCKEN បានស្បថ នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៣ ហើយលោកត្រូវបានចុះក្នុងបញ្ជីមេធាវី នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៥។*

*លោកជាសមាជិកនៅការិយាល័យមេធាវី ABOUCAYA – VERCKEN – KAIL - ALBIN ។*

*២- __អង្គហេតុចោទប្រកាន់__*

*លោក Arthur VERCKEN និងលោកស្រី GUISSÉ ជាមេធាវីការពារក្តីលោក ខៀវ សំផន ដែលត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។*

***១) ជនជាប់ចោទ***

*លោក ខៀវ សំផន បច្ចុប្បន្ន អាយុ ៨៤ ឆ្នាំ ជាអតីតប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ (ជាឈ្មោះដែលខ្មែរក្រហមបានដាក់ឲ្យប្រទេសកម្ពុជា ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៩ ហើយរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ នៅ*

ឆ្នាំ១៩៧៩)។ លោក ខៀវ សំផន កំពុងត្រូវបានជំនុំជម្រះ រួមជាមួយលោក នួន ជា បច្ចុប្បន្ន អាយុ ៨៩ ឆ្នាំ ជាអតីតប្រធានសភាតំណាងប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ និងអតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា។

**២) អ.វ.ត.ក**

អ.វ.ត.ក គឺជាតុលាការឯកភាជ្យ ដែលត្រូវបានបង្កើតឡើងតាមច្បាប់កម្ពុជា ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម។ អ.វ.ត.ក បើកដំណើរការ តាំងពីឆ្នាំ ២០០៧។ អ.វ.ត.ក មានសមាសភាពចៅក្រមកម្ពុជា និងចៅក្រមអន្តរជាតិ។ ជាក់ស្តែង ក្នុងរឿងក្តីវិវាទអង្គជំនុំជម្រះសាលាដំបូងមានចៅក្រមម្នាក់ជាជនជាតិបារាំង និងចៅក្រមម្នាក់ទៀតជាជនជាតិអូទ្រីស ក្នុងចំណោមចៅក្រមទាំងប្រាំរូប។

អ.វ.ត.ក ទទួលរងនូវការរិះគន់មិនឈប់ឈរថា ស្ថិតនៅក្រោមឥទ្ធិពលនយោបាយនៃរាជរដ្ឋាភិបាលកម្ពុជា (ដែលមិនចង់ឱ្យកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមឱ្យបានឆាប់) មានភាពយឺតយ៉ាវ និងគ្មានប្រសិទ្ធភាព។ ពិតណាស់ រហូតមកទល់នឹងសព្វថ្ងៃនេះ តុលាការនេះទទួលបានសំណុំរឿងតែបួនប៉ុណ្ណោះ ដោយសារសហព្រះរាជអាជ្ញាអន្តរជាតិបង្ហាញចេតនាកាលពីពេលថ្មីៗកន្លងទៅនេះថា ខ្លួនមិនចោទប្រកាន់បន្ថែមទៀតទេ។

**៣) សំណុំរឿងវិវាទ**

សំណុំរឿងវិវាទ គឺសំណុំរឿង ០០២ ដែលមានលោក ខៀវ សំផន និងលោក នួន ជា ជាជនជាប់ចោទ។ រឿងក្តីនេះត្រូវបានបើក នៅឆ្នាំ២០០៧ ហើយជនជាប់ចោទទាំងពីររូបត្រូវបានឃុំខ្លួនបណ្តោះអាសន្ន តាំងពីពេលនោះរហូតមក។ ដំបូងឡើយ រឿងក្តីនេះមានជនជាប់ចោទពីររូបផ្សេងទៀត គឺលោក អៀង សារី និងភរិយា លោកស្រី អៀង ធីរិទ្ធ។ ប៉ុន្តែ លោក អៀង សារី បានទទួលមរណភាព នៅឆ្នាំ២០១៣ ឯលោកស្រី អៀង ធីរិទ្ធ ត្រូវបានតុលាការប្រកាសថា មិនមានសម្បទាក្នុងការចូលរួមសវនាការ ពីព្រោះលោកស្រីមានជំងឺវង្វេងវង្វាន់ដោយសារវ័យចាស់ជរា។

សហចៅក្រមស៊ើបអង្កេតបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ (កម្រាស់ជិត ៨០០ ទំព័រ) នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០។ ក្រោយមក សំណុំរឿង ០០២ ត្រូវបានបំបែកជាពីរវគ្គ៖

- **សំណុំរឿង ០០២/០១** ផ្តោតលើការជម្លៀសប្រជាជនដោយបង្ខំ ដែលត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការសម្លាប់ទាហានស្មោះត្រង់នឹងរដ្ឋាភិបាលដែលត្រូវបានខ្មែរក្រហមផ្តួលរំលំនៅឆ្នាំ ១៩៧៥។ បើតាមព័ត៌មាននៅក្នុងវ៉េបសាយត៍របស់ អ.វ.ត.ក៖

*“សំណុំរឿងនេះក៏មានកម្មវត្ថុពិនិត្យលើតួនាទីរបស់ជនជាប់ចោទ នៅក្នុងគោលនយោបាយទាំងមូល ដែលមានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសារតែគោលនយោបាយទាំងនេះគឺជាមូលដ្ឋាននៃការចោទប្រកាន់ ដែលនឹងត្រូវពិនិត្យនៅក្នុងការជំនុំជម្រះក្តីវគ្គក្រោយៗទៀត”។*

- ***សំណុំរឿង ០០២/០២*** *ផ្តោតលើអង្គហេតុដែលមិនត្រូវបានពិនិត្យ ក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០១ ជាពិសេស ការចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍។ ដូចបានលើកឡើងខាងលើ សំណុំរឿង ០០២/០១ មានឥទ្ធិពលលើជោគវាសនានៃបទចោទ នៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០២។ មេធាវី ដែលទទួលរងនូវការចោទប្រកាន់ បានបញ្ជាក់អំពីចំណុចនេះ នៅក្នុងសវនាការ។*

### ៤) កិច្ចដំណើរការនីតិវិធី

*ការជំនុំជម្រះក្តីសំណុំរឿង ០០២/០១ បានប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលមានលោក និល ណុន ចៅក្រមកម្ពុជា ជាប្រធាន និងមានសមាសភាព លោក Jean-Marc LAVERGNE ចៅក្រមបារាំង លោក យ៉ា សុខន ចៅក្រមកម្ពុជា លោកស្រី Claudia FENZ ចៅក្រមអូទ្រីស និងលោក យូរ ឧត្តរា ចៅក្រមកម្ពុជា។*

*ក្រៅពីលោក VERCKEN និងលោកស្រី GUISSÉ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន មានសមាភាព លោក គង់ សំអុន មេធាវីកម្ពុជា អ្នកពិគ្រោះយោបល់ច្បាប់មួយរូប និងមន្ត្រីគ្រប់គ្រងសំណុំរឿងមួយរូប។ ទន្ទឹមនឹងនេះ ក្រុមមេធាវីការពារក្តីមានកម្មសិក្សាការីពីររូប។ ក្រុមមួយទៀតដែលមានសមាសភាពស្រដៀងគ្នានេះ ទទួលបន្ទុកការពារក្តីលោក នួន ជា (រួមទាំងមេធាវីហូល្លង់ លោក KOPPE)។*

*បើតាមព័ត៌មាននៅក្នុងវែបសាយត៍របស់ អ.វ.ត.ក (DC 57) ការិយាល័យសហព្រះរាជអាជ្ញាមានបុគ្គលិកអចិន្ត្រៃយ៍ សហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញារង ជំនួយការ អ្នកស៊ើបអង្កេត អ្នកវិភាគ អ្នកស្រាវជ្រាវ ក្រឡាបញ្ជី និងអ្នកបកប្រែ សរុបចំនួន ២៧ នាក់ ព្រមទាំងមានកម្មសិក្សាការី ១២ រូប ក៏ដូចជា មន្ត្រីមួយចំនួនទៀតមកពីតុលាការកម្ពុជា។*

*បើតាមចម្លើយនៅក្នុងសវនាការរបស់មេធាវីដែលទទួលរងនូវការចោទប្រកាន់ ក្រុមសហព្រះរាជអាជ្ញា ក្នុងសំណុំរឿង ០០២ មានយ៉ាងហោចណាស់ មេធាវីអន្តរជាតិប្រាំរូប និងមេធាវីកម្ពុជាជាច្រើនរូប។*

សាលក្រមត្រូវបានប្រកាស នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។ ជនជាប់ចោទត្រូវបានទទួលស្គាល់ថាមានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

ជនជាប់ចោទទាំងពីររូបបានប្តឹងសាទុក្ខ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល នៃ អ.វ.ត.ក។ ការធ្វើបណ្តឹងសាទុក្ខមានរយៈពេលខ្លី គឺ ៣០ ថ្ងៃ សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និង ៦០ ថ្ងៃ សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ។ ដោយសារតែការងារនេះមានទំហំធំធេង (ឧទាហរណ៍ សាលក្រមមានជាង ៧៥០ ទំព័រ) អង្គជំនុំជម្រះតុលាការកំពូលបានបន្ថែមពេលវេលា ៣០ ថ្ងៃ ដល់ជនជាប់ចោទក្នុងការដាក់សារណាបណ្តឹងសាទុក្ខ គឺរហូតដល់ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ តាមរយៈសេចក្តីសម្រេច ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤។

នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលវិភាគសវនាការនៃសំណុំរឿង ០០២/០២ ដោយត្រូវចាប់ផ្តើមពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ តទៅ ដែលនេះគឺជាដើមហេតុបណ្តាលឲ្យមានការប្តឹងឲ្យចាត់វិធានការខាងវិន័យ។

### ៥) ការលំបាកដែលជាដើមហេតុនៃបណ្តឹងនេះ

ជាដំបូង មេធាវីដែលទទួលរងនូវការចោទប្រកាន់ បានអះអាងថា ដោយសារតែសំណុំរឿង ០០២/០១ និង សំណុំរឿង ០០២/០២ មានទំនាក់ទំនងនឹងគ្នា វាជាការចាំបាច់ត្រូវ "រង់ចាំសាលក្រមស្ថាពរនៃសំណុំរឿង ០០២/០១ សិន មុននឹងចាប់ផ្តើមសំណុំរឿង ០០២/០២"។ មេធាវីក៏បានដាក់សេចក្តីសន្និដ្ឋានក្នុងន័យនេះ នៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៤។ សំណើនេះត្រូវបានបដិសេធ ដោយសេចក្តីសម្រេច ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤។

ក្រោយមក មេធាវីបានស្នើថា ដោយសារតែកូនក្តីរបស់ខ្លួនត្រូវបានផ្តន្ទាទោស នៅក្នុងសំណុំរឿង ០០២/០១ សវនាការនៃសំណុំរឿង ០០២/០២ មិនត្រូវចាប់ផ្តើម មុនពេលបញ្ចប់ការតាក់តែងសារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ នោះឡើយ។ ដូច្នេះ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ កាលពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ លោកស្រី GUISSÉ បានប្រកាសថា៖

> "ខ្ញុំគិតថា ខ្ញុំមិនធ្វើឲ្យនរណាម្នាក់ភ្ញាក់ផ្អើលនោះទេ ក្នុងការលើកឡើងម្តងទៀតនូវអ្វីដែលមេធាវីការពារក្តីលោក ខៀវ សំផន តែងតែនិយាយ ក្នុងកិច្ចប្រជុំមុនៗ និងក្នុងកិច្ចប្រជុំរៀបចំសវនាការរួចមកហើយ គឺថា ដោយសារតែកង្វះធនធានមនុស្ស និងដោយសារតែសារៈសំខាន់នៃការងារធ្វើ

> បណ្ដឹងសាទុក្ខ យើងខ្ញុំមិនអាចសរសេរបណ្ដឹងសាទុក្ខផង ចូលរួមសវនាការ និងត្រៀមខ្លួនសម្រាប់សវនាការផងនោះទេ។ ដូច្នេះ យើងខ្ញុំស្នើឱ្យសវនាការលើសំណុំរឿង ០០២/០២ ចាប់ផ្ដើម ក្រោយពេលយើងខ្ញុំដាក់សារណាបណ្ដឹងសាទុក្ខរួចសិន"។

នៅពេលនោះ មិនមានចម្លើយតបទៅនឹងសំណើនេះទេ។

នៅ<u>ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤</u> ក្រោយពេលចេញសាលក្រមផ្ដន្ទាទោសរួច មេធាវីការពារក្ដីលោក ខៀវ សំផន បានដាក់សំណើថ្មីមួយទៀត សុំលើកពេលចាប់ផ្ដើមសវនាការលើសំណុំរឿង ០០២/០២ រហូតដល់សាលក្រមលើសំណុំរឿង ០០២/០១ ចូលជាស្ថាពរសិន។ សំណើនេះត្រូវបានបដិសេធ ដោយសេចក្ដីសម្រេច ចុះ<u>ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤</u>។

នៅថ្ងៃដដែលនោះដែរ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាកំណត់កាលបរិច្ឆេទសវនាការលើសំណុំរឿង ០០២/០២។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចចាប់ផ្ដើមសវនាការ នៅ<u>ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤</u> និងបន្តរហូតដល់<u>ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤</u> ប៉ុន្តែ កាត់បន្ថយចំនួនថ្ងៃធ្វើសវនាការ មកនៅត្រឹមតែ ៣ ថ្ងៃ ក្នុងមួយសប្ដាហ៍ ដើម្បីទុកពេលវេលាឱ្យភាគីសរសេរសារណាបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១។

នៅ<u>ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៤</u> មេធាវីការពារក្ដីលោក ខៀវ សំផន បានដាក់សំណើជាថ្មីម្ដងទៀត សុំលើកពេលចាប់ផ្ដើមសវនាការលើសំណុំរឿង ០០២/០២ ដោយរំឭកថា ខ្លួនមិនអាច "ចូលរួមសវនាការលើសំណុំរឿង ០០២/០២ ផង និងតាក់តែងសារណាបណ្ដឹងសាទុក្ខផងនោះទេ ពីព្រោះវានឹងបង្កព្យសនកម្មដល់លោក ខៀវ សំផន"។ មេធាវីការពារក្ដីបានលើកឡើងថា ជាក់ស្ដែង ការចូលរួមរបស់គាត់ក្នុងការតាក់តែងសារណាមានសារៈសំខាន់ណាស់។

នៅ<u>ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤</u> អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនេះ ជាថ្មីម្ដងទៀត។

សូមបញ្ជាក់ថា ទន្ទឹមនឹងនេះ នៅក្នុងសំណុំរឿង ០០២/០២ មេធាវីការពារក្ដីបានដាក់បណ្ដឹងជំទាស់...

ដូច្នេះ លោក ខៀវ សំផន បានបង្គាប់ឲ្យមេធាវីរបស់ខ្លួនផ្តោតលើការតាក់តែងសារណាបណ្តឹងសាទុក្ខ និង កុំឲ្យចូលរួមសវនាការលើសំណុំរឿង ០០២/០២ របស់អង្គជំនុំជម្រះសាលាដំបូង។

ជាក់ស្តែង នៅក្នុងសវនាការថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ លោក ខៀវ សំផន បានប្រកាសថា៖

> "អង្គជំនុំជម្រះបានបង្ខំឲ្យខ្ញុំធ្វើ ហើយខ្ញុំយល់ថាមិនយុត្តិធម៌ទេ ដែលអស់លោករុញច្រានឲ្យខ្ញុំធ្លាក់ក្នុងសភាពការណ៍បែបនេះ។ តែបើគ្មានផ្លូវណាជ្រើសរើសនោះទេ ខ្ញុំត្រូវបង្ខំចិត្តជម្រាបមេធាវីខ្ញុំឲ្យធ្វើយ៉ាងណាដើម្បីសារណាបណ្តឹងឧទ្ធរណ៍ (...)។ មានន័យថាគាត់ពុំអាចមកចូលរួមសវនាការក្នុងការកាត់ក្តីសំណុំរឿង ០០២/០២ បានទេ (...)។
>
> ខ្ញុំសូមជម្រាបលោកប្រធានថា នៅពេលណាដែលមេធាវីខ្ញុំ និងខ្ញុំ រៀបចំសារណាឧទ្ធរណ៍បានចប់សព្វគ្រប់ ហើយយកទៅដាក់ទាន់ពេលវេលា ខ្ញុំទាំងអស់គ្នាក៏ត្រឡប់មកចូលសវនាការនេះវិញ"។

នៅក្នុងសវនាការថ្ងៃដដែលនោះ លោកស្រី GUISSÉ បានបញ្ជាក់ថា ទាំងនេះជាសេចក្តីបង្គាប់របស់កូនក្តី។ ដូច្នេះ មេធាវីការពារក្តីនាំគ្នាចាកចេញពីសវនាការ។ មេធាវីការពារក្តីលោក នួន ជា បានប្រកាន់ជំហរដូចគ្នានេះផងដែរ។

ក្រោយពីសវនាការនោះ អង្គជំនុំជម្រះសាលាដំបូងបានកោះហៅមេធាវីការពារក្តីឲ្យចូលរួមកិច្ចប្រជុំរៀបចំសវនាការ នៅ<u>ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤</u>។ មេធាវីការពារក្តីមិនបានមានវត្តមាននោះទេ។

ក្រោយពីចេញសេចក្តីព្រមានដល់មេធាវី នៅ<u>ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤</u> អង្គជំនុំជម្រះសាលាដំបូងបានរៀបចំកិច្ចប្រជុំរៀបចំសវនាការជាថ្មីម្តងទៀត នៅ<u>ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤</u>។ ប៉ុន្តែ លើកនេះ មេធាវីការពារក្តីបានចូលរួម។

ក្រោយពីសវនាការនោះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាត់បន្ថយចំនួនថ្ងៃធ្វើសវនាការមកនៅត្រឹមតែ ២ ថ្ងៃ ក្នុងមួយសប្តាហ៍ (ត្រូវជា ៤ ថ្ងៃសវនាការ នៅខែវិច្ឆិកា និង ៦ ថ្ងៃសវនាការ នៅខែធ្នូ) តាមរយៈសេចក្តីសម្រេច ចុះ<u>ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤</u>។ អង្គជំនុំជម្រះក៏បានបញ្ជាក់ផងដែរថា អង្គជំនុំជម្រះ "នឹងពិចារណាយ៉ាងយកចិត្តទុកដាក់លើសំណើសុំធនធានបន្ថែមរបស់មេធាវីការពារក្តី" លោក ខៀវ សំផន។

តាមរយៈសេចក្តីសង្កេតជាលាយលក្ខណ៍អក្សរ ចុះ<u>ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤</u> មេធាវីការពារក្តីបាន

បញ្ជាក់ជំហររបស់ខ្លួនឡើងវិញ ដូចខាងក្រោម៖

> “លោក ខៀវ សំផន និងមេធាវីរបស់គាត់ មានបំណងបញ្ជាក់សាជាថ្មីម្តងទៀតអំពីជម្រើសរបស់ខ្លួនក្នុងការមិនចូលរួមសវនាការលើសំណុំរឿង ០០២/០២ ដរាបណាខ្លួនមិនទាន់បញ្ចប់ការតាក់តែងសារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ពោលគឺ រហូតដល់ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ពីព្រោះថានេះគឺជាកាលបរិច្ឆេទចុងក្រោយដែលបានកំណត់ដោយតុលាការកំពូល”។

នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ប្រធានអង្គជំនុំជម្រះសាលាដំបូងបានសម្រេចចាត់តាំងមេធាវីការពារក្តីលោក ខៀវ សំផន ជាមេធាវីរបស់តុលាការ ដោយសង្ឃឹមថាពួកគេនឹងចូលរួមសវនាការ។ លោក Arthur VERCKEN លោក គង់ សំអុន និងលោកស្រី Anta GUISSÉ បានឆ្លើយតប តាមរយៈលិខិត ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ដោយបដិសេធការតែងតាំងនេះ ពីព្រោះវាផ្ទុយនឹងក្រមសីលធម៌វិជ្ជាជីវៈ ដោយសារតែការតែងតាំងនេះមានគោលដៅ “មិនឱ្យពួកគាត់គោរពតាមការណែនាំរបស់ជនជាប់ចោទកុំឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធី”។

បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យផ្នែកគាំពារការការពារក្តី (អង្គភាពមួយរបស់ អ.វ.ត.ក ទទួលបន្ទុកគ្រប់គ្រងមេធាវីការពារក្តី) តែងតាំងមេធាវីប្រចាំការ តាមរយៈសេចក្តីសម្រេច ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៤។

នៅទីបំផុត សវនាការលើសំណុំរឿង ០០២/០២ បានចាប់ផ្តើម នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ ដោយមានវត្តមានរបស់មេធាវីដែលទទួលរងនូវការចោទប្រកាន់។

### ៦/ ការដាក់ពាក្យបណ្តឹងមកអាជ្ញាធរចោទប្រកាន់

តាមរយៈសេចក្តីសម្រេច ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ដែលត្រូវបានបញ្ជូនមកដោយអនុស្សរណៈ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ របស់ប្រធានអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដាក់ពាក្យបណ្តឹងមកប្រធានគណៈមេធាវីក្រុងប៉ារីស និងលោកអគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ក្រុងប៉ារីសពាក់ព័ន្ធនឹង “កំហុសវិជ្ជាជីវៈរបស់មេធាវី Arthur VERCKEN និងមេធាវី Anta GUISSÉ”។ អង្គជំនុំជម្រះសាលាដំបូងបានចោទប្រកាន់មេធាវីទាំងពីររូបថាបានធ្វើឱ្យ “រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី” តាមរយៈ “ការរំលោភបំពានលើសេចក្តីបង្គាប់របស់តុលាការឱ្យចូលរួមសវនាការ”។

ក្នុងល័ក្ខខ័ណ្ឌទាំងនេះហើយទើបនីតិវិធីវិន័យត្រូវបានបើក។

## III- នីតិវិធីវិន័យ

តាមរយៈលិខិតប្តឹង និងបើកនីតិវិធីវិន័យ ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥ លោកប្រធានគណៈមេធាវីតំណាងអាជ្ញាធរចោទប្រកាន់ បានសម្រេចបើកនីតិវិធីវិន័យលើលោកមេធាវី Arthur VERCKEN៖

- ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងដោយចេតនាលើកាតព្វកិច្ចវិជ្ជាជីវៈ ដោយមិនគោរពតាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក ឱ្យចូលរួមសវនាការ និងការពារក្តីលោក ខៀវ សំផន ដែលទង្វើនេះបង្កឱ្យមានភាពគ្មានរបៀបរៀបរយនៃសវនាការដែលបានគ្រោងទុក និងធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងបង្ខំចិត្តលើកពេលបើកសវនាការលើសំណុំរឿង ០០២/០២។

ការប្រព្រឹត្តិនេះផ្ទុយទៅនឹងគោលការណ៍ជាសារវ័ន្តនៃវិជ្ជាជីវៈមេធាវី វិរិយភាព សតិសម្បជញ្ញៈ ស្មោះត្រង់ មិនប្រាថ្នាប្រយោជន៍ និងភក្តីភាព ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃប្រការ ១.៣ នៃបទបញ្ជាផ្ទៃក្នុងជាតិ។

លិខិតប្តឹងត្រូវបានជូនដំណឹងទៅលោក VERCKEN តាមរយៈសំបុត្រអនុសិដ្ឋ ដោយមានបង្កាន់ដៃទទួលនៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥។

តាមរយៈសេចក្តីសម្រេច ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៥ ក្រុមប្រឹក្សាគណៈមេធាវីបានចាត់តាំងលោក Denis CHEMLA សមាជិកក្រុមប្រឹក្សាគណៈមេធាវី និងជាសមាជិកគណៈស៊ើបអង្កេត ឱ្យធ្វើជាអ្នកស៊ើបអង្កេត។

លោក VERCKEN ត្រូវបានជូនដំណឹងអំពីការចាត់តាំងនេះ តាមរយៈលិខិតចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៥។

តាមរយៈសំបុត្រអនុសិដ្ឋ ដោយមានបង្កាន់ដៃទទួល នៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៥ អ្នកស៊ើបអង្កេតបានកោះហៅលោក VERCKEN ឱ្យមកចូលរួមសវនាការ នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥ វេលាម៉ោង ៩ និង ៣០ នាទី ព្រឹក។

*កំណត់ហេតុមួយត្រូវបានធ្វើឡើងដោយអ្នកស៊ើបអង្កេត និងចុះហត្ថលេខាដោយលោក VERCKEN។*

*របាយការណ៍ស៊ើបអង្កេតត្រូវបានដាក់ នៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ដោយមានសេចក្តីសន្និដ្ឋានដូចខាងក្រោម៖*
*"ផ្អែកលើព័ត៌មានដែលប្រមូលបាននៅក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត គណៈវិនិច្ឆ័យជាអ្នកត្រូវសម្រេចថា តើមេធាវីដែលទទួលរងនូវការចោទប្រកាន់ បានប្រព្រឹត្តខុសនឹងក្រមសីលធម៌វិជ្ជាជីវៈដែរឬទេ នៅពេលពួកគេគោរពតាមសេចក្តីណែនាំរបស់កូនក្តីមិនឱ្យចូលរួមសវនាការរបស់ អ.វ.ត.ក ចាប់ពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤"។*

**អាស្រ័យហេតុនេះ**

## II- សំអាងហេតុ

ដោយយល់ឃើញថា លោក Arthur VERCKEN ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តផ្ទុយនឹងគោលការណ៍ជាសារវន្តនៃវិជ្ជាជីវៈមេធាវី វីរិយភាព សតិសម្បជញ្ញៈ ស្មោះត្រង់ មិនប្រាថ្នាប្រយោជន៍ និងភក្តីភាព ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃប្រការ ១.៣ នៃបទបញ្ជាផ្ទៃក្នុងជាតិ ដោយសារតែមិនបានគោរពតាមសេចក្តីបង្គាប់របស់តុលាការ។

ជាក់ស្តែង លោក Arthur VERCKEN ទំនងជាបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងដោយចេតនាលើកាតព្វកិច្ចវិជ្ជាជីវៈ ដោយមិនគោរពតាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក ឱ្យចូលរួមសវនាការ និងការពារក្តីលោក ខៀវ សំផន ដែលទង្វើនេះបង្កឱ្យមានភាពគ្មានរបៀបរៀបរយនៃសវនាការដែលបានគ្រោងទុក និងធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងបង្ខំចិត្តលើកពេលបើកសវនាការលើសំណុំរឿង ០០២/០២។

ដូច្នេះ សំណួរសួរថា តើការមិនគោរពតាមសេចក្តីបង្គាប់របស់តុលាការ ទោះជាក្នុងកាលៈទេសៈបែបណាក៏ដោយ គឺជាការល្មើសនឹងក្រមសីលធម៌ដែរឬទេ?

លោក Arthur VERCKEN និងលោកស្រី Anta GUISSÉ ជាមេធាវីការពារក្តីលោក ខៀវ សំផន ដែល

ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានប្រព្រឹត្តក្នុងអំឡុងពេលគាត់ដឹកនាំអតីតរដ្ឋកម្ពុជាប្រជាធិបតេយ្យ។ ការជំនុំជម្រះក្តីលោក ខៀវ សំផន បានប្រព្រឹត្តទៅនៅចំពោះមុខ អ.វ.ត.ក ជាតុលាការឯករាជ្យ ដែលត្រូវបានបង្កើតឡើងតាមច្បាប់កម្ពុជា ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម។

អ.វ.ត.ក មានសមាសភាពចៅក្រមកម្ពុជា និងចៅក្រមអន្តរជាតិ។ ដូច្នេះ អ.វ.ត.ក ជាតុលាការមានលក្ខណៈកូនកាត់។

ជនជាប់ចោទ ក្នុងនោះ មានលោក ខៀវ សំផន ត្រូវបានបញ្ជូនទៅជំនុំជម្រះ តាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះ (កម្រាស់ ៨០០ ទំព័រ) ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០។ សំណុំរឿងនេះត្រូវបានបែងចែកជាពីរវគ្គ ដែលវគ្គទីមួយ (សំណុំរឿង ០០២/០១) ផ្តោតលើការជម្លៀសប្រជាជនដោយបង្ខំ និងវគ្គទីពីរ (សំណុំរឿង ០០២/០២) ផ្តោតជាអាទិ៍លើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

សាលក្រមលើសំណុំរឿង ០០២/០១ ត្រូវបានប្រកាស នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ហើយជនជាប់ចោទត្រូវបានទទួលស្គាល់ថាមានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

ជនជាប់ចោទ ក្នុងនោះ មានលោក ខៀវ សំផន បានប្តឹងសាទុក្ខ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក។ ការធ្វើបណ្តឹងសាទុក្ខមានរយៈពេលខ្លី គឺ ៣០ ថ្ងៃ សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និង ៦០ ថ្ងៃ សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ។

ដោយសារតែការងារនេះមានទំហំធំធេង លោក Arthur VERCKEN និង លោកស្រី Anta GUISSÉ បានស្នើសុំបន្ថែមពេលវេលាដាក់សារណាបណ្តឹងសាទុក្ខ ដែលនាំឱ្យមានបញ្ហាស្មុគស្មាញផ្នែកនីតិវិធី ដូចបានរៀបរាប់នៅក្នុងសេចក្តីថ្លែងហេតុ និងដីកាកោះ។

ក្នុងល័ក្ខខ័ណ្ឌទាំងនេះហើយទើបប្រធានអង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក បានប្តឹងទៅអគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ក្រុងប៉ារីស អនុលោមតាមវិធាន ៣៨(២) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

ពាក្យបណ្តឹងបានរៀបរាប់អំពីការប្រព្រឹត្តិរបស់មេធាវីការពារក្តីលោក ខៀវ សំផន ដែលក្នុងនោះ ទង្វើរបស់មេធាវី VERCKEN និងមេធាវី GUISSÉ ត្រូវបានចាត់ទុកថាបានធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី យោងតាមវិធាន ៣៨(១) នៃវិធានផ្ទៃក្នុង។

ជារួម នៅក្នុងពាក្យបណ្តឹង ប្រធានអង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក បានស្តីបន្ទោសថា ការបដិសេធរបស់លោក VERCKEN និងលោកស្រី GUISSÉ ក្នុងការមិនចូលរួមក្នុងសវនាការនៃសំណុំរឿង ០០២/០២ បានធ្វើឱ្យបាត់បង់ការជំនុំជម្រះក្តីចំនួន ២៥ ថ្ងៃ ក្នុងរយៈពេល ១០ សប្តាហ៍ ហើយដោយសារតែវ័យចាស់ជរារបស់ជនជាប់ចោទ សាក្សី និងជនរងគ្រោះ ការពន្យារពេលណាមួយអាចនឹងនាំឱ្យពួកគេមិនអាចចូលរួមក្នុងការជំនុំជម្រះបាន។

យោងតាមវិធាន ៣៨(១) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ក្រោយពេលព្រមានអាចដាក់ទណ្ឌកម្ម ឬបដិសេធក្នុងការចូលរួមសវនាការចំពោះមេធាវីណាមួយ ប្រសិនបើយល់ឃើញថាការប្រព្រឹត្តរបស់មេធាវីរូបនោះ ជាការប្រមាថមើលងាយ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី រំលោភទៅលើរឿងក្តី ឬផ្ទុយទៅនឹងមាត្រា ២១-៣ នៃកិច្ចព្រមព្រៀង។

យោងតាមវិធាន ៣៨(២) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចបញ្ជូនករណីកំហុសវិជ្ជាជីវៈនេះទៅអង្គភាពមានសមត្ថកិច្ច។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមវិធាននេះ។

យោងតាមឯកសារលេខ ៨ ដែលបានដាក់ឱ្យពិភាក្សាដេញដោល ដើម្បីការពារក្តី មេធាវីបានចុះកិច្ចសន្យាជាមួយអង្គការសហប្រជាជាតិ និងបានចុះកិច្ចសន្យា "ផ្តល់សេវាផ្លូវច្បាប់" (ឯកសារលេខ ៣២)។

សូមបញ្ជាក់ផងដែរថា មេធាវីការពារក្តី នៅចំពោះមុខ អ.វ.ត.ក មិនបានស្បថនៅចំពោះមុខតុលាការនេះទេ ហើយមិនត្រូវស្ថិតនៅក្រោមនីតិវិធី common law ដែលត្រូវបានហៅថាការ "ប្រមាថមើលងាយតុលាការ" នោះទេ។

ផ្ទុយទៅវិញ មេធាវីបានស្បថ នៅចំពោះមុខគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (ឯកសារលេខ ១៦ របស់លោកស្រី GUISSÉ)។ អាស្រ័យហេតុនេះ មេធាវីការពារក្តី នៅចំពោះមុខតុលាការកម្ពុជា ត្រូវគោរព

តាមវិធានរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវប្រតិបត្តិតាមក្រមសីលធម៌មេធាវីរបស់គណៈមេធាវី។ ដូច្នេះ នៅពេលមានមេធាវីណាម្នាក់មិនគោរពតាមក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គេត្រូវប្ដឹងមេធាវីរូបនោះទៅក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ករណីនេះដូចគ្នាទៅនឹងករណីរបស់លោក គង់ សំអុន ជាមេធាវីកម្ពុជានៃក្រុមការពារក្ដីលោក ខៀវ សំផន ក្នុងក្របខ័ណ្ឌនៃសំណុំរឿងដូចគ្នា ហើយគាត់បានប្រកាន់ឥរិយាបថដូចគ្នាក្នុងការការពារក្ដី ដោយបដិសេធមិនចូលរួមសវនាការនៅអង្គជំនុំជម្រះសាលាដំបូង ដរាបណាមេធាវីការពារក្ដីមិនទាន់ដាក់សារណាបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១។

តាមរយៈសេចក្ដីសម្រេចរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥ គណៈមេធាវីបានចាត់ទុកថាការប្រព្រឹត្តិរបស់លោក គង់ សំអុន មិនមែនជាកំហុសវិជ្ជាជីវៈមេធាវីនោះទេ។

វាជារឿងសមហេតុសមផលដែលលោក Arthur VERCKEN ត្រូវបានចោទប្រកាន់ តាមសំណើរបស់អគ្គរដ្ឋអាជ្ញា នៅចំពោះមុខក្រុមប្រឹក្សាវិន័យនៃគណៈមេធាវីក្រុងប៉ារីស ពាក់ព័ន្ធនឹងការប្រព្រឹត្តិខុសក្រមសីលធម៌វិជ្ជាជីវៈដូចបានលើកឡើងដោយប្រធានអង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក។

ជាការពិតណាស់ ពេលការពារក្ដីនៅចំពោះមុខ អ.វ.ត.ក មេធាវីត្រូវគោរពវិធានផ្ទៃក្នុងរបស់តុលាការនេះដូចជាភាគីនៅក្នុងក្របខ័ណ្ឌនៃនីតិវិធីមជ្ឈត្តការ ត្រូវគោរពតាមវិធានមជ្ឈត្តការ ដូច្នេះដែរ។ ការមិនគោរពវិធានផ្ទៃក្នុង ឧបមាថាវាផ្ទុយនឹងគោលការណ៍ជាសារវ័ន្តនៃវិជ្ជាជីវៈមេធាវី អាចនាំឲ្យមានការប្ដឹងទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងគណៈមេធាវីក្រុងប៉ារីស។

ប្រធានគណៈមេធាវីក្រុងប៉ារីសបានរំឭក នៅក្នុងមតិយោបល់ផ្លូវច្បាប់ (ឯកសារលេខ ៩ របស់លោកស្រី GUISSÉ) ថា មេធាវីចុះឈ្មោះនៅគណៈមេធាវីក្រុងប៉ារីសត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈមេធាវីក្រុងប៉ារីសជានិច្ច ពាក់ព័ន្ធនឹងបញ្ហាក្រមសីលធម៌វិជ្ជាជីវៈ ទោះបីជាបំពេញការងារ នៅចំពោះមុខតុលាការច្បាប់ជាតិ ឬអន្តរជាតិក៏ដោយ និងទោះជាក្នុងករណីលើកលែងក៏ដោយ។ មតិយោបល់នេះរំឭកផងដែរថា បើតាមប្រព័ន្ធច្បាប់បារាំង ដែលជាប្រព័ន្ធច្បាប់ civil law មេធាវីត្រូវអនុវត្តតាមអាណត្តិដែលកូនក្ដីប្រគល់ឲ្យតាមរយៈកិច្ចសន្យា និងមិនមែនជាជំនួយការតុលាការនោះទេ គឺជាជំនួយការយុត្តិធម៌ ពីព្រោះខ្លួនតំណាងឲ្យផលប្រយោជន៍ផ្ទាល់មុខរបស់កូនក្ដី។

លោកស្រី GUISSÉ និងលោក VERCKEN បានដាក់សេចក្ដីសង្កេតជាលាយលក្ខណ៍អក្សរ នៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥ ជូនលោក Jean-Marc FEDIDA អ្នកសម្របសម្រួលនៃអាជ្ញាធរចោទប្រកាន់។

លោក Arthur VERCKEN បានសម្រេចយកទឡ្ហីករណ៍ការពារខ្លួនដូចគ្នានឹងលោកស្រី GUISSÉ ដែរ។ លោកស្រី GUISSÉ ចូលមកបង្ហាញខ្លួននៅចំពោះមុខគណៈវិនិច្ឆ័យ ហើយបានលើកឡើងនូវទឡ្ហីករណ៍ដូចខាងក្រោម៖

លោកស្រីជំទាស់យ៉ាងដាច់អហង្ការទៅនឹងការចោទប្រកាន់ពីបទប្រព្រឹត្តកំហុសវិជ្ជាជីវៈមេធាវី ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ លោកស្រីយល់ឃើញថាការចោទប្រកាន់នេះកើតចេញពីការមិនយល់អំពីកាតព្វកិច្ចវិជ្ជាជីវៈមេធាវី និងការមើលស្រាលលើការងាររបស់មេធាវីការពារក្ដី។

លោកស្រីរំឭកថា ខ្លួនបានបំពេញការងារ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ជាមួយលោក VERCKEN ជាអាទិ៍ នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ហើយលោកស្រីមិនធ្លាប់ត្រូវបានចោទប្រកាន់ថាមិនគោរពវិជ្ជាជីវៈ នៅក្នុងតួនាទីជាអ្នកការពារក្ដី ទាល់តែសោះ។

លោកស្រីបញ្ជាក់ថា ការស៊ើបអង្កេតលើសំណុំរឿងលោក ខៀវ សំផន បានប្រព្រឹត្តទៅអស់រយៈពេលបីឆ្នាំ ហើយការពិភាក្សាសម្រេចរបស់ចៅក្រម ដែលឈានទៅដល់ការផ្ដន្ទាទោសលោក ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិត បានប្រព្រឹត្តទៅអស់រយៈពេល ១០ ខែ។ ក្នុងរយៈពេលដ៏យូរនៃការពិភាក្សាសម្រេចរបស់ចៅក្រម អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់សហព្រះរាជអាជ្ញាសុំចាប់ផ្ដើមសវនាការលើសំណុំរឿង ០០២/០២។

លោកស្រីក៏រៀបរាប់លម្អិតផងដែរអំពីការប្រែប្រួលនីតិវិធីនៃសំណុំរឿង ដែលជាឧបសគ្គរាំងស្ទះមិនឲ្យគាត់មានលទ្ធភាពត្រៀមខ្លួន សម្រាប់សវនាការលើសំណុំរឿង ០០២/០២ និងតាក់តែងសារណាបណ្ដឹងសាទុក្ខ (ក្រោយពីចេញសាលក្រមនៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤) ២៣០ ទំព័រ ក្នុងរយៈពេលដ៏ខ្លីបំផុត ហើយត្រូវជំទាស់តវ៉ាទៅនឹងនីតិវិធីដែលមានសវនាការរយៈពេលពីរឆ្នាំ ក្នុងនោះមានសក្ខីកម្មសាក្សីជិត ១០០ នាក់ និងកំណត់ហេតុសវនាការរាប់ម៉ឺនទំព័រ។

លោកស្រី GUISSÉ ពន្យល់ថាគឺក្នុងល័ក្ខខ័ណ្ឌបែបនេះហើយដែលកូនក្តីរបស់គាត់បានបង្គាប់យ៉ាងម៉ឺងម៉ាត់ឲ្យមេធាវីការពារក្តីផ្តោតទាំងស្រុងលើការតាក់តែងសារណាបណ្តឹងសាទុក្ខ និងកុំឲ្យចូលរួមសវនាការលើសំណុំរឿង ០០២/០២ ដើម្បីឲ្យមេធាវីការពារក្តីមានពេលវេលាគ្រប់គ្រាន់សរសេរសារណាបណ្តឹងសាទុក្ខ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងមិនលើកពេលបើកសវនាការ តាមការស្នើសុំនោះទេ។

លោកស្រី និងក្រុមមេធាវីការពារក្តី យល់ឃើញថា ដោយមានការឯកភាពពីកូនក្តី ដោយសារបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ មានសារៈសំខាន់ក្នុងការថែរក្សាផលប្រយោជន៍របស់កូនក្តីខ្លួនគ្មានជម្រើសអ្វីផ្សេងក្រៅពីស្នើសុំផ្អាក នៅពេលចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ នោះទេ។ ក្រោយមក ក៏កើតមានភាពតានតឹងដាក់គ្នារវាងមេធាវីការពារក្តី និងអង្គជំនុំជម្រះសាលាដំបូង។

លោកស្រីលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងហាក់ដូចជាយល់ឃើញថា មេធាវីការពារក្តីត្រូវតែស្តាប់បង្គាប់របស់តុលាការ។ ផ្ទុយទៅវិញ ក្នុងទស្សនៈនៃការការពារក្តី ដែលមាននៅក្នុងប្រព័ន្ធច្បាប់ civil law និងអនុលោមតាមគោលការណ៍ក្រមសីលធម៌វិជ្ជាជីវៈ មេធាវីការពារក្តីមានឯករាជ្យភាព និងមិនទទួលបញ្ជាពីតុលាការឡើយ គឺមេធាវីការពារក្តីបំពេញការងារ ទៅតាមសេចក្តីណែនាំរបស់កូនក្តី ឲ្យតែសេចក្តីណែនាំនោះស្របទៅនឹងផលប្រយោជន៍យុត្តិធម៌ និងមិនរំលោភបំពានលើគោលការណ៍ជាសារវ័ន្ត។

លោកស្រី GUISSÉ ផ្តល់ឯកសារមួយចំនួន និងជាអាទិ៍ កិច្ចសន្យាដែលភ្ជាប់កាតព្វកិច្ចរបស់មេធាវីការពារក្តីជាមួយនឹងអង្គការសហប្រជាជាតិ។ កិច្ចសន្យានោះបញ្ជាក់ថា លោកស្រីត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈនៃគណៈមេធាវីកម្ពុជា និងគណៈមេធាវីក្រុងប៉ារីស ហើយមិនត្រូវបានបកស្រាយថាអាចបង្កឧបសគ្គរាំងស្ទះដល់សេចក្តីណែនាំរបស់កូនក្តីឡើយ។

ទោះជាយ៉ាងនេះក្តី ដូចបានរៀបរាប់ពីខាងលើ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វិធានដែលមេធាវីការពារក្តីត្រូវតែគោរពជាចាំបាច់ និងយល់យ៉ាងច្បាស់ អនុញ្ញាតឲ្យប្តឹងចោទប្រកាន់អំពីការប្រព្រឹត្តិខុសក្រមសីលធម៌ទៅគណៈមេធាវីរបស់មេធាវីសាមី។

អាជ្ញាធរចោទប្រកាន់ គឺប្រធានគណៈមេធាវីក្រុងប៉ារីស រំឭកថា មេធាវីមិនបានស្បថថានឹងគោរពវិធានផ្ទៃក្នុងរបស់តុលាការនោះទេ និងបញ្ជាក់ថាកិច្ចសន្យាដែលចុះជាមួយអង្គការសហប្រជាជាតិមិនចែងឲ្យគោរពវិធានផ្ទៃក្នុងនោះទេ គឺគ្រាន់តែចែងអំពីល័ក្ខខ័ណ្ឌបង់ប្រាក់កម្រៃជូនមេធាវីតែប៉ុណ្ណោះ។

អាជ្ញាធរចោទប្រកាន់រំឭកផងដែរថា នៅចំពោះ អ.វ.ត.ក ជាតុលាការកូនកាត់ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានតែនៅក្នុងច្បាប់ civil law និងគ្មាននៅក្នុងច្បាប់ common law ត្រូវបានអនុញ្ញាត ដែលនេះជាវឌ្ឍនភាពមួយ។

ចំពោះការការពារក្តីជនជាប់ចោទ មេធាវីមិនស្ថិតនៅក្រោមឱវាទតុលាការនោះទេ និងមិនមែនជា "មន្ត្រីរបស់តុលាការ" ដូចនៅក្នុងច្បាប់ common law នោះទេ គឺមេធាវីមានឯករាជ្យភាពក្នុងឋានៈជាជំនួយការយុត្តិធម៌។

ម្យ៉ាងវិញទៀត អាជ្ញាធរចោទប្រកាន់យល់ឃើញថា លោក Arthur VERCKEN និងក្រុមមេធាវីការពារក្តីបានប្រើប្រាស់សិទ្ធិរបស់ខ្លួន ដើម្បីបំពេញយ៉ាងស្ងប់ចិត្តនូវបេសកកម្មដែលកូនក្តីប្រគល់ឱ្យ និងមិនបានរាំងស្ទះដល់ការអនុវត្តការងាររបស់ អ.វ.ត.ក នោះទេ។

ជាចុងក្រោយ អាជ្ញាធរចោទប្រកាន់យល់ឃើញថា នៅពេលប្រឈមនឹងភាពចាំបាច់បំផុតក្នុងការតាក់តែងសារណាបណ្តឹងសាទុក្ខ ក្នុងរយៈពេលដ៏ខ្លី ខណៈដែលសំណុំរឿង ០០២/០២ មានហានិភ័យខ្ពស់ចំពោះកូនក្តីដូចសំណុំរឿង ០០២/០១ ដែរ ហើយសវនាការមានលក្ខណៈចាប់បង្ខំ លោក Arthur VERCKEN និងក្រុមមេធាវីការពារក្តីគ្មានជម្រើសអ្វីផ្សេងក្រៅពីប្រកាន់យកឥរិយាបថផ្ទាល់ខ្លួន ស្របទៅតាមសេចក្តីណែនាំរបស់កូនក្តី និងនៅតែរក្សាបាននូវសេចក្តីគោរពចំពោះចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង។

ដូច្នេះ អាជ្ញាធរចោទប្រកាន់ទុកភារៈនេះជូនក្រុមប្រឹក្សាវិន័យជាអ្នកសម្រេច។

គណៈវិនិច្ឆ័យយល់ឃើញថា ឆ្លងតាមការសិក្សាលើសំណុំរឿង ឯកសារដែលផ្តល់ជូនដោយមេធាវីការពារក្តី និងសេចក្តីពន្យល់របស់មេធាវីការពារក្តី លោក Arthur VERCKEN មិនបានប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌នោះទេ គឺខុសពីការលើកឡើងក្នុងពាក្យបណ្តឹងថា មេធាវីការពារក្តីបានធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី និងបានរំលោភបំពានលើសេចក្តីបង្គាប់របស់តុលាការឱ្យចូលរួមសវនាការ។

មេធាវីការពារក្តីបានស្នើសុំឱ្យផ្អាកសវនាការ ដែលរាំងមិនឱ្យតាក់តែងសារណាបណ្តឹងសាទុក្ខ ដែលមានបញ្ហាប្រឈមធ្ងន់ធ្ងរ មេធាវីការពារក្តីនៅតែបំពេញតួនាទីរបស់ខ្លួន មិនមានចេតនារាំងយុត្តិធម៌នោះទេ

ហើយបើទោះបីជាមេធាវីការពារក្តីមិនគោរពតាមសេចក្តីបង្គាប់របស់តុលាការ ក៏មេធាវីការពារក្តីធ្វើដោយឯករាជ្យ។

ជាពិសេស មេធាវីការពារក្តីបានគោរពសេចក្តីណែនាំយ៉ាងម៉ឺងម៉ាត់ និងជាក់លាក់របស់លោក ខៀវ សំផន ដែលជំទាស់មិនឱ្យមេធាវីចូលរួមក្នុងសវនាការនៃសំណុំរឿង ០០២/០២ ដរាបណាមិនទាន់សរសេរសារណាបណ្តឹងសាទុក្ខលើសំណុំរឿង ០០២/០១ ចប់សព្វគ្រប់។

ប៉ុន្តែ ទោះបីជាតុលាការអាចតែងតាំងមេធាវីណាម្នាក់ជាមេធាវីរបស់តុលាការ នៅពេលត្រូវការជំនួយពីមេធាវីជាចាំបាច់ ទុកណាជាជនជាប់ចោទមិនចង់បានក៏ដោយ ក៏តុលាការមិនអាចបង្ខំឱ្យមេធាវីការពារក្តីជនជាប់ចោទបានឡើយ។

ដូច្នេះ ការខកខាននេះមិនយូរនោះទេ គឺត្រឹមតែពេលសរសេរបញ្ចប់សារណាបណ្តឹងសាទុក្ខប៉ុណ្ណោះ ពោលគឺមួយខែ ហើយចាប់ពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ មក លោក Arthur VERCKEN និងលោកស្រី Anta GUISSÉ បានចូលរួមសវនាការឡើងវិញ ដើម្បីការពារក្តីកូនក្តីរបស់ខ្លួន នៅក្នុងសំណុំរឿង ០០២/០២។

ភាពគ្មានរបៀបរៀបរយដែលអាចកើតមានចំពោះអង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក បើទោះជាអាចមានភាពក្តៅក្រហាយក៏ដោយ គ្រាន់តែបណ្តោះអាសន្នតែប៉ុណ្ណោះ ហើយមិនបង្កព្យសនកម្មដល់ការស្វែងរកយុត្តិធម៌ឡើយ។ សូមរំឮកថា ចំពោះការចោទប្រកាន់អំពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត ត្រូវតែធានាបាននូវការគោរពសិទ្ធិរបស់មេធាវីការពារក្តីឱ្យបានជាអតិបរមា។

ដូច្នេះ ក្រុមប្រឹក្សាវិន័យយល់ឃើញដូចគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលបានសម្រេចលើករណីដូចគ្នានេះមុនខ្លួនដែរ គឺថា លោក Arthur VERCKEN មិនបានប្រព្រឹត្តខុសនឹងគោលការណ៍ជាសារវន្តនៃវិជ្ជាជីវៈមេធាវីនោះទេ និងជាពិសេស មិនបានប្រព្រឹត្តខុសនឹងគោលការណ៍វីរិយភាព សតិសម្បជញ្ញៈ ស្មោះត្រង់ មិនប្រាថ្នាប្រយោជន៍ និងភក្តីភាព ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃប្រការ ១.៣ នៃបទបញ្ជាផ្ទៃក្នុងជាតិ នោះទេ។

ដូច្នេះ ក្រុមប្រឹក្សាវិន័យសម្រេចថាពាក្យបណ្តឹងចោទប្រកាន់មិនមានមូលដ្ឋានត្រឹមត្រូវ។

# អាស្រ័យហេតុនេះ

ដោយប្រកាសជាសាធារណៈ ចំពោះមុខ និងបើកផ្លូវតវ៉ា

**សម្រេច**

**ប្រការ ១÷** ទទួលយកពាក្យបណ្តឹងរបស់អាជ្ញាធរចោទប្រកាន់។

**ប្រការ ២÷** សម្រេចថា លោក Arthur VERCKEN មិនបានប្រព្រឹត្តខុសនឹងគោលការណ៍ជាសារវ័ន្តនៃវិជ្ជាជីវៈមេធាវីនោះទេ។

**ប្រការ ៣÷** ប្រកាសលើកលែងការចោទប្រកាន់។

**ប្រការ ៤÷** សេចក្តីសម្រេចនេះនឹងត្រូវជូនដំណឹងដល់លោក Arthur VERCKEN និងចម្លងជូនលោកស្រីអគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ក្រុងប៉ារីស និងលោកប្រធានគណៈមេធាវីក្រុងប៉ារីស។

**ប្រការ ៥÷** ក្នុងរយៈពេល**មួយខែ**ចាប់ពីកាលបរិច្ឆេទជូនដំណឹង សាមីជនអាចបញ្ជូនសេចក្តីសម្រេចនេះទៅកាន់សាលាឧទ្ធរណ៍ក្រុងប៉ារីស តាមរយៈសេចក្តីប្រកាសទៅលេខាធិការដ្ឋានក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ឬតាមរយៈសំបុត្រអនុសិដ្ឋ ដោយមានបង្កាន់ដៃទទួល ផ្ញើទៅលេខាធិការដ្ឋានក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។

លោកស្រីអគ្គរដ្ឋអាជ្ញា និងលោកប្រធានគណៈមេធាវីត្រូវទទួលបានការជូនដំណឹងតាមរយៈសំបុត្រអនុសិដ្ឋ ដោយមានបង្កាន់ដៃទទួល។

**វត្តមាន÷**

លោកប្រធានគណៈមេធាវី Paul-Albert IWEINS ប្រធានគណៈវិនិច្ឆ័យទីមួយ លោក Etienne LESAGE លេខាធិការ សមាជិកក្រុមប្រឹក្សាគណៈមេធាវី លោក Jean-Louis MAGNIER លោកស្រី Hélène POIVEY-LECLERCQ លោក Jean-Jacques UETTWILLER អតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវី។

| | |
|---|---|
| **លេខាធិការគណៈវិនិច្ឆ័យទីមួយ** | **ប្រធានគណៈវិនិច្ឆ័យទីមួយ** |
| *[ហត្ថលេខា]* | *[ហត្ថលេខា]* |
| **លោក Etienne LESAGE** | **ប្រធានគណៈមេធាវី Paul-Albert IWEINS** |